# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ០២៣/១៤ ក.ប/ស.ណ.ន

# សេចក្តីណែនាំ

## ស្តីពី

## ការផ្តល់សេវារកការងារក្នុងប្រទេសជូនដល់ពលករទេសន្តរប្រវេសន៍ ដែលទើបវិលត្រឡប់ពីព្រះរាជាណាចក្រថៃឡង់ដ៍ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តលិខិតលេខ ៩០៣សជណ អរ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការដោះស្រាយ និងរកការងារក្នុងប្រទេសជូនពលករទេសន្តប្រវេសន៍ខ្មែរដែលទើបវិលត្រឡប់ពីព្រះរាជាណាចក្រថៃឡង់ដ៍ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់ពលករ និងប្រជាពលរដ្ឋដូចខាងក្រោម ៖

### ១.-ការទទួលព័ត៌មានអំពីឱកាសការងារ និងការចុះឈ្មោះជួយរកការងារក្នុងប្រទេស

បច្ចុប្បន្នក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រមូលនូវព័ត៌មានស្តីពីតម្រូវការកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ឧស្សាហកម្ម សំណង់ និងសេវាកម្មបានចំនួនប្រមាណជា ៣៩,០០០កន្លែង ពីបណ្តាក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាសនានាទាំងនៅក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តនានា ជាពិសេសនៅខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ សៀមរាប បន្ទាយមានជ័យ តាកែវ ស្វាយរៀង ព្រះសីហនុ និងកោះកុង។ ក្រសួងនឹងបន្តប្រមូលចងក្រង និងផ្សព្វផ្សាយព័ត៌មានឱកាសការងារពីបណ្តាគម្រោងវិនិយោគនានា ជាពិសេសពីគម្រោងវិនិយោគបរទេស។

ទន្ទឹមនឹងការផ្សព្វផ្សាយព័ត៌មានស្តីពីឱកាសការងារនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត បាននឹងកំពុងរៀបចំវេទិកាការងារនៅតាមស្រុក និងខេត្តមួយចំនួន (កម្មវិធីជ្រើសរើសកម្លាំងពលកម្មចល័ត) ដោយនាំទៅជាមួយនូវម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលកំពុងមានតម្រូវការកម្លាំងពលកម្មចុះទៅពន្យល់បង្ហាញអំពីឱកាសការងារ និងលក្ខខណ្ឌការងារ និងជ្រើសរើសកម្លាំងពលកម្មដល់មូលដ្ឋានតែម្តង។

ដើម្បីទទួលបាននូវព័ត៌មានអំពីឱកាសការងារ និងសេវាជួយរកការងារដូចបានជម្រាបជូនខាងលើសូមពលករខ្មែរដែលទើបត្រឡប់មកពីព្រះរាជាណាចក្រថៃឡង់ដ៍ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើមេត្តាអញ្ជើញទៅទំនាក់ទំនង និងចុះឈ្មោះនៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការ ទៅតាមទីកន្លែងណាមួយដូចខាងក្រោម៖

- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈទូរសព្ទលេខ ០១១ ៨៩៨ ៩១២ ឬ០១២ ៩៣៩ ២៩៣ ឬ០១២ ៩២៨ ៧៦៩ ឬ ០១២ ៧០៧ ៧៨៧។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈ ទូរសព្ទលេខ ០១២ ៦៦៦ ៥៩១ ឬគេហទំព័រ www.nea.gov.kh។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដែលនៅក្បែរទីលំនៅដ្ឋាន។
- មជ្ឈមណ្ឌលការងារទាំង៧ ដែលមានទីតាំងនៅ៖
    - មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ ទូរសព្ទលេខ ០២៣ ៦៣៣ ៦០០២ ឬ០៧៧ ២៣២ ៣៧៨
    - មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង ទូរសព្ទលេខ ០៥៣ ៧៣៣ ១១១ ឬ ០១៦ ៩២៦ ៦៥៥
    - មជ្ឈមណ្ឌលការងារខេត្តសៀមរាប ទូរសព្ទលេខ ០៦៣ ២១០ ២៧៧ ឬ ០១៦ ៥៣៦ ៦៥៥
    - មជ្ឈមណ្ឌលការងារខេត្តកំពត ទូរសព្ទលេខ ០៣៣ ២១០ ២៧៧ ឬ ០១៦ ៥០៦ ៦៥៥
    - មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង ទូរសព្ទលេខ ០៤៤ ៧១៥ ២៧៧ ឬ ០១៦ ៦៤៦ ៦៥៥
    - មជ្ឈមណ្ឌលការងារខេត្តកំពង់ចាម ទូរសព្ទលេខ ០៤២ ២១០ ២៧៧ ឬ ០១៦ ៦៥៦ ៦៥៥
    - មជ្ឈមណ្ឌលការងារខេត្តតាកែវ ទូរសព្ទលេខ ០៣២ ២១០ ២៧៧ ឬ ០១៦ ៦៧៦ ៦៥៥

**២-ឱកាសទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

ចំពោះពលរដ្ឋ ដែលមានបំណងចង់អភិវឌ្ឍជំនាញវិជ្ជាជីវៈសូមទៅចុះឈ្មោះសុំចូលរៀនជំនាញនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំង៣៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលស្ថិតនៅតាមរាជធានី-ខេត្តទាំង២៥ ដែលមានអាសយដ្ឋាននៅក្បែរលំនៅដ្ឋានរបស់ខ្លួន។

ចំពោះពលករដែលទើបវិលត្រឡប់មកពីព្រះរាជាណាចក្រថៃឡង់ដ៍ ក្រសួងបានរៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញខ្លីផ្នែកកសិកម្ម ឧស្សាហកម្ម បច្ចេកទេស សិប្បកម្ម ទេសចរណ៍ សំណង់ និងសេវាកម្ម ដោយឥតគិតថ្លៃជាច្រើនវគ្គដែលរយៈពេលចាប់ពី ១សប្តាហ៍ ដល់ ៤ខែ។

ចំពោះព័ត៌មានលម្អិត សាធារណជនអាចទាក់ទង សាកសួរព័ត៌មាននៅ គ្រប់មន្ទីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃរាជធានី-ខេត្ត ឬគ្រប់មជ្ឈមណ្ឌលការងារ នៅរៀងរាល់ម៉ោង និងថ្ងៃធ្វើការ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យ ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- -គ្រប់មន្ទីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ